# ប្រពៃណីជីកសត្វល្អីងរបស់ជនជាតិកួយ

ជនជាតិកួយ ជាជនជាតិមួយក្នុងចំណោមជនជាតិដើមភាគតិចទាំង២៤ក្រុមក្នុងប្រទេសកម្ពុជា ដែលមានវត្តមាននៅតំបន់វាលទំនាបខាងជើងបឹងទន្លេសាប ក្នុងទឹកដីនៃខេត្តព្រះវិហារ ខេត្តកំពង់ធំ និងមានតិចតួចនៅខេត្តក្រចេះ។ ជនជាតិនេះរក្សាបាននូវវប្បធម៌ ប្រពៃណី និងទំនៀមទំលាប់រហូតមកដល់បច្ចុប្បន្ន មានដូចជា ភាសា ជំនឿ និងល្បែងល្បាំ សម្រាប់ការប្រតិបត្តិក្នុងសហគមន៍ ជាដើម។ ពួកគេភាគច្រើន រស់នៅដោយការប្រកបរបរចិញ្ចឹមជីវិត ពឹងលើការធ្វើកសិកម្មពនាចរ ការប្រមែប្រមូលអនុផលពីព្រៃឈើ និងមុខរបរផ្សេងៗជាប្រពៃណីរបស់ពួកគេ។

សំណេរផ្លូវការក្នុងវចនានុក្រមខ្មែរសរសេរថា "រពីង"។ ប៉ុន្តែ ភាសាអ្នកស្រុកនៅកំពង់ធំច្រើនហៅសត្វនេះថា "ល្អីង" និងអ្នកផងទូទៅច្រើនធ្លាប់ស្គាល់ថា "អាពីង"។ ជាធម្មតា តាមមាត់ខ្មែរជាពិសេសអ្នកនៅកំពង់ធំ អក្សរ "រ" តែងរត់ទៅជាអក្សរ "ល" មិនមានអ្វីចម្លែកនោះទេ ឧទាហរណ៍ពាក្យ "រពាក់" គេច្រើននិយាយថា "ល្អាក់"។ រពីង ជាសត្វមានរូបសណ្ឋានស្រដៀងនឹងពីងពាងធំ មានចង្កូមខុប ធ្វើរន្ធរស់នៅក្នុងដី ព័ទ្ធសរសៃចាក់ស្រេះភ្ជិតមាត់រន្ធ។ រពីង មានពីរយ៉ាង គឺរពីងគោ មានរូបតូច សម្បុរប្រផេះ និងរពីងក្របី មានសម្បុរខ្មៅ រូបធំជាងរពីងគោ[១] (រូបលេខ១)។

នៅពេលយើងធ្វើដំណើរចេញពីខេត្តសៀមរាបទៅរាជធានីភ្នំពេញ យើងតែងតែប្រទះឃើញគេលក់សត្វរពីងបំពងនៅទីប្រជុំជនស្គន់ ខេត្តកំពង់ចាម។ អ្នកលក់នៅទីនោះតែងប្រាប់យើងថា ពួកគាត់បានទិញសត្វនេះមកពីខេត្តកំពង់ធំ ភាគច្រើនស្រុកប្រាសាទសំបូរ ស្រុកសណ្ដាន់ ស្រុកប្រាសាទបល្ល័ង្គ និងស្រុកស្ទោង។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញជូនអំពីប្រពៃណីជីកសត្វល្អីងរបស់ជនជាតិកួយ ដែលរស់នៅក្នុងភូមិវាលវែង ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មកបង្ហាញ។ តើជនជាតិកួយជីកសត្វល្អីងមានលក្ខណៈពិសេសបែបណាខ្លះ?

ការជីកសត្វល្អីងមិនសូវមានភាពពិបាកប៉ុន្មានឡើយ ពោល គឺគេគ្រាន់ប្រើប្រាស់ចបជីកមួយ និងដបមួយសម្រាប់ច្រកសត្វល្អីងគឺគ្រប់គ្រាន់ហើយ។ ជនជាតិកួយតែងសម្គាល់ថា សត្វល្អីងច្រើនធ្វើរន្ធរស់នៅក្បែរមាត់ទឹក ដូចជា បឹង ត្រពាំង ជាដើម។ គេសម្គាល់ថា រន្ធរបស់សត្វល្អីង គឺមានសសៃពណ៌សគ្របពីលើរន្ធដូចសំបុកសត្វពីងពាងដែលយើងតែងជួបក្នុងផ្ទះដែរ (រូបលេខ២)។

---

[១] ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ៩៩៩

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# អត្ថបទ៖ ប្រពៃណីជីកសត្វល្អីងរបស់ជនជាតិកួយ

កាលណាបើឃើញរន្ធរបស់សត្វល្អីងមួយហើយ គេត្រូវសម្គាល់ថា តើរន្ធរបស់វាបែរមុខទៅណា? ប្រសិនបើរន្ធបែរមុខទៅទិសខាងជើង គេត្រូវដើររកមើលទៅទិសខាងជើងប៉ុន្មានម៉ែត្រពីគ្នានឹងច្បាស់ជាឃើញរន្ធរបស់មួយទៀតមិនខាន។ ក្នុងការជីកសត្វល្អីង គេត្រូវជីកតាមសម្រួល មិនបង្ខំពេកទេ ដោយត្រូវជីកបញ្ឆិតបញ្ឆៀង ព្រោះវាអាចធ្វើឱ្យជីកប៉ះចំល្អីង ដែលនាំឱ្យសត្វល្អីងដាច់ខ្លួនជាពីរកំណាត់ ឬងាប់ (រូបលេខ២៣)។ ដ្បិតបំណងរបស់អ្នកជីក គឺចង់បានសត្វល្អីងនៅរស់ និងមានរូបរាងល្អ។ ជាទូទៅ ជីកដល់ជម្រៅដីចាប់ពី ០,១៥ម៉ែត្រ ដល់ ០,២៥ម៉ែត្រ នឹងជួបសត្វល្អីងហើយ។ ពេលជីកជួបសត្វល្អីង គេតែងចាប់សត្វល្អីងកាច់ធ្មេញរបស់វាចោល ដ្បិតធ្មេញរបស់វាមានពិសដែលអាចខាំមនុស្សនាំឱ្យឈឺចុកចាប់បាន។ ប្រការមួយដែលគួរឱ្យចាប់អារម្មណ៍ពីប្រពៃណីរបស់ជនជាតិកួយ គឺពេលគេកាច់ធ្មេញរបស់ល្អីងគេមានសូត្រឃ្លាមួយថា "**កាច់ជើងច អជើងធូ**"។ ឃ្លានេះជាភាសាកួយដែលប្រែថា "**កាច់ជើងខ្លែ ល្អជើងល្អីង**"។ ពាក្យ "អ" ត្រូវនឹងភាសាខ្មែរថា "ល្អ" រីឯពាក្យ "ធូ" ត្រូវនឹងភាសាខ្មែរថា "ល្អីង"។ ជនជាតិកួយជឿថា ការសូត្រនេះគឺជាបាលីមួយដើម្បីកុំឱ្យសត្វល្អីងខាំ និងក្នុងបំណងសូមឱ្យសត្វល្អីងនៅរក្សារូបរាងដើមបានល្អ ពោល គឺកាច់តែធ្មេញចោលប៉ុណ្ណោះ។ ការកាច់ធ្មេញសត្វល្អីង គេត្រូវយកម្រាមដៃចាប់ក្តោបជើងសត្វល្អីង ហើយយកធ្មេញសត្វល្អីងមកផ្ទឹបជាប់នឹងផ្ទៃចបជីក រួចយកក្រចកមេដៃកាច់ធ្មេញរបស់ល្អីង(រូបលេខ២៤)។ បន្ទាប់ពីកាច់ធ្មេញរួចរាល់ គេយកញាត់ល្អីងចូលក្នុងដបជាការស្រេច (រូបលេខ២៥)។ នៅលើគម្របដបគេត្រូវចោះរន្ធបន្តិច ដើម្បីមានខ្យល់ចេញចូលខ្លះ បង្ការកុំឱ្យល្អីងងាប់។

អ្នកជីកល្អីងជាជនជាតិកួយប្រាប់ថា ជាទូទៅល្អីងសម្បូណ៌និងមានរូបរាងធំធាត់ខ្លាំងនៅរវាងខែពិសាខ ពោល គឺដើមរដូវធ្លាក់ភ្លៀង។ ពួកគាត់តែងលក់សត្វល្អីងដែលជីកបានទៅឱ្យឈ្មួញកណ្តាលក្នុងមួយក្បាលតម្លៃចាប់ពី ៣០០ ដល់ ១០០០ រៀល តាមតូចតាមធំ។ ពេលខ្លះគាត់មិនលក់ទេ គឺយកអាំងពិសារ និងដាក់ត្រាំស្រាក៏បាន។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ១-២៖ សត្វល្ពីង និងរន្ធសត្វល្ពីង



រូបលេខ៣៖ ការជីកសត្វល្ពីង



រូបលេខ៤៖ ការកាច់ធ្មេញសត្វល្ពីង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ញាត់ល្អីងចូលដប

## ឯកសារយោង

ពុទ្ធសាសនបណ្ឌិត្យ

១៩៦៧, វចនានុក្រមខ្មែរ, ភ្នំពេញ